សេដាកឆ្នាំទី៣ លេខ១១ ទំព័ទី៣)

**♦របៀបរៀបចំធ្វើសំបុកកូនជ្រូកៈ**

ជាធម្មតាកូនជ្រូកដែលទើបនឹងកើតត្រូវការផ្តល់កំដៅជាបន្ទាន់ ព្រោះស្បែករបស់វាស្តើង និង មានជាតិខ្លាញ់តិច។ ដូចនេះ ដើម្បីរក្សាសុខភាពរបស់កូនជ្រូកទើបនឹងកើតឱ្យបានល្អ ត្រូវផ្តល់កំដៅឱ្យបានគ្រប់គ្រាន់ដោយធ្វើសំបុកឱ្យកូនជ្រូក អោយបានកក់ក្តៅ។ សំបុកនេះត្រូវបានរៀបចំទុកមុននៅពេលកូនជ្រូកកើត ជៀសវាងកុំអោយកូនជ្រូកងាប់ដោយសារខ្វះកំដៅ។ កូនជ្រូកដែលខ្វះកំដៅអាចបណ្តាលឱ្យវាបាក់កំលាំងចុះខ្សោយដែលប៉ះ ពាល់ដល់ការលូតលាស់របស់វាម្យ៉ាងវិញទៀត សំបុកនេះ ជួយកាត់បន្ថយនូវអត្រាស្លាប់របស់កូនជ្រូកដោយប្រការ ផ្សេងៗដូចជាការជាន់ឬសង្កត់ដោយមេរបស់វាជាដើម។

**♦របៀបរៀបចំសំបុកជ្រូក ៈ**

សំបុកជ្រូកអាចធ្វើពីបន្ទះក្តារហើយក្រាលចំបើងពីក្នុង ការក្រាលចំបើងនេះមានផលប្រយោជន៏ក្នុងការ ផ្តល់កំដៅដល់កូនជ្រូកទប់ទល់នឹងភាពត្រជាក់ និងបឺតសំណើមបំបាត់ក្លិនស្អុយ ហើយអាចធ្វើជាឧបករណ៏សំរាប់កូនជ្រូកលេងផងដែរ។ ម្យ៉ាងទៀត ក៏បង្កលក្ខណៈអោយដល់មេជ្រូកក្នុងការកាច់សំបុក។ សំរាប់កូនជ្រូក១០ក្បាល ត្រូវធ្វើសំបុកដែលមានទទឹង៨តឹកទៅ ១ម៉ែត្របណ្តោយ ១ម៉ែត្រ៣តឹកនិងកំពស់៦តឹកហើយក្នុងការយកឧបករណ៏មកធ្វើសំបុកត្រូវ ប្រយ័ត្នពីព្រោះវាធ្វើអោយកូនជ្រូកមាន របួស។



ការផ្តល់កំដៅ និង របៀបការពារកូនជ្រូកតាមបែបផ្សេងទៀតគឺ គេដាក់កូនជ្រូកក្នុងទ្រុងជាមួយមេវា ដោយមានរបាំងព័ទ្ធ ជុំវិញសំរាប់កូនជ្រូកនិងក្រាលចំបើង ពីក្រោមផងដែរ ការធ្វើរបៀបនេះនៅពេលដែលកូនជ្រូកចេះស៊ីចំណី គេអាចដាក់ចំណីអាហារឱ្យកូនជ្រូកស៊ីនៅក្នុង បរិវេណដែលហ៊ុំព័ទ្ធនោះ ធ្វើយ៉ាងនេះមេជ្រូក មិនអាចចូល ស៊ីបាន។

(ដកស្រង់ពីទស្សនាវដ្តី កសិករ ប្រចាំខែឆ្នាំទី៥ លេខ០៩ ,កញ្ញា ២០០៣, ទំព័រទី ៦-៧ របស់អង្គការសេដាក់)




ទ្រុងកូនជ្រូកជួយការពារកំដៅ

ស្នូកទឹក និង ចំណីសំរាប់កូនជ្រូក

ស្នូកចំណី



**ទ្រុងជ្រូកសំរាប់មេបំបៅកូនដោយមានរបាំងសំរាប់កូនជ្រូក**



**padek**

# កត្តាអ្វីខ្លះដែលធ្វើអោយជ្រូកមិនឈឺនិងឆាប់ធំ

**១.បើយើងចិញ្ចឹមជ្រូកត្រូវមើលពូជគឺៈ**

♦ជ្រើសរើសយកជ្រូកពូជធំ (មើលមេ ឬ បារបស់ជ្រូក)។
♦ជ្រើសរើសពូជដែលធន់នឹងជំងឺមកចិញ្ចឹម។♦កូនជ្រូកត្រូវមានអាយុ ២ខែមកចិញ្ចឹម។♦គួរជៀសវាងជ្រូកមិនស្គាល់ប្រវត្តិច្បាស់លាស់។



ជ្រើសរើសជ្រូក ដងខ្លួនរាងកោងប្រសើរជាងខ្នង រាបស្មើ និង ខ្នងអែន។

**២.បើយើងចិញ្ចឹមជ្រូកត្រូវមានទ្រុងគឺៈ**

♦ទ្រុងជ្រូកត្រូវធ្វើយ៉ាងណាអោយមានពន្លឺថ្ងៃចាំងចូលក្នុងទ្រុងនៅពេលព្រឹក ទ្រុងត្រូវស្អាតជានិច្ច គ្មានភក់។
♦ទ្រុងត្រូវលៃ យ៉ាងណាការពារបាននូវកំដៅថ្ងៃ ទឹកភ្លៀង និង ភាពត្រជាក់។



**៣.បើយើងចិញ្ចឹមជ្រូក ត្រូវមើលទឹក និង ចំណីគឺៈ**

•ផ្តល់ទឹកស្អាតអោយជ្រូកផឹកគ្រប់ពេល ពេញ១ថ្ងៃ។
•ផ្តល់ចំណីអោយជ្រូកស៊ីអោយបានឆ្អែត និង ទៀងទាត់។
•ត្រូវដាំបន្លែដូចជាចេក ល្ហុង ត្រកួន បន្លែ និង រុក្ខជាតិផ្សេងៗសំរាប់ធ្វើចំណីដូចជា ដើមកន្ទំថេត។
•ទិញម្សៅប្រីមិច (Pre-mix) មកលាយចំណីអោយជ្រូកស៊ី ព្រោះវាសំបូរវីតាមីន និង ធ្វើអោយជ្រូកឆាប់ធំ។
•ចាក់ថ្នាំជាតិដែកអោយជ្រូក ពិសេសពេលកូនជ្រូកអាយុបាន៣ថ្ងៃ និង ពេលអាយុបាន២១ថ្ងៃម្តងទៀត។ ខ្វះជាតិដែកធ្វើអោយជ្រូក អន់ចំណី និង មិនធំធាត់។




## ៤.បើយើងចិញ្ចឹមជ្រូក ត្រូវធ្វើអនាម័យ:

•សំអាតទ្រុងអោយស្អាតជានិច្ច សំអាតស្នូកទឹក និង ស្នូក



ចំណីរៀងរាល់ថ្ងៃ ជៀសវាងទុកអោយផ្អូម។ •តាមដានសុខភាពជ្រូកជារៀងរាល់ថ្ងៃ។ •បើមានជ្រូកឈឺត្រូវចាប់បំបែកជ្រូកឈឺចេញភ្លាម រួចហៅពេទ្យសត្វភូមិមកមើលជាបន្ទាន់ មិនត្រូវទុកអោយជ្រូកឈឺយូរឡើយ។ •រាល់៣ខែម្តងត្រូវចាក់ថ្នាំទំលាក់ព្រូនអោយជ្រូក។•ត្រូវចាក់វ៉ាក់សាំងអោយជ្រូកដើម្បីការពារជំងឺ។



## ៥.បើយើងចិញ្ចឹមជ្រូក ត្រូវថែទាំជ្រូក:

•កូនជ្រូកតូចៗមិនអាចទ្រំនឹងភាពត្រជាក់បានឡើយ ត្រូវធ្វើកន្លែងអោយវាដេកនៅពេលយប់មានលក្ខណៈជាបន្ទប់តូចបិទជិត មានតំបូល និង មានផ្លូវចូល។
•កូនជ្រូកត្រូវរស់នៅកន្លែងស្ងួត ចំណីកូនជ្រូកត្រូវរំលាយ និង ជីវជាតិខ្ពស់។



## ៦.បើយើងចិញ្ចឹមជ្រូកត្រូវស្វែងរកបទពិសោធន៍គឺ:



•ឧស្សាហ៍ពិភាក្សាជាមួយអ្នកភូមិ ឬ អ្នកមកពីខាងក្រៅដើម្បីសាកសួរពីបទពិសោធន៍ល្អៗ ពីការចិញ្ចឹមជ្រូកដើម្បីយកមកអនុវត្តន៍ក្នុងការចិញ្ចឹមរបស់យើង។

## ៧.បើយើងចិញ្ចឹមជ្រូកត្រូវអនុវត្តន៍នូវបទពិសោធន៍គឺ:

ខាងក្រោមនេះជាបទពិសោធន៍ ដែលកសិករមួយចំនួនបានអនុវត្តន៍កន្លងមក:

**•<u>បទពិសោធន៍ប្រើប្រាស់ចកបាយទា ជាចំណីជ្រូក</u>**

(បទពិសោធន៍ចិញ្ចឹមជ្រូកកូន២ក្បាល):

-កូនជ្រូកចាប់ពីអាយុ១ខែកន្លះរហូតដល់ខែគឺមិនទាន់ផ្តល់ បន្លែអោយស៊ីទេ ព្រោះកូនជ្រូកនៅតូចប្រព័ន្ធរំលាយអាហាររបស់វាមិនទាន់ដំណើរការស្រួលទេ។ ដូច្នេះចំណីដែលត្រូវផ្តល់វាស៊ីមានតែបាយនិងកន្ទក់គឺលាយបាយកន្លះគីឡូក្រាមកន្ទក់២ខាំច្របល់លាយជាមួយទឹកភក់ៗហើយផ្តល់អោយវាស៊ីមួយថ្ងៃ២ដង
-កូនជ្រូកអាយុ៣ខែបន្ទាប់ពីក្រៀវរួចហើយ ការផ្តល់ចំណីក៏មានការផ្លាស់ប្តូរដែរ គឺត្រូវបន្ថែមនូវបន្លែខ្លះៗ។ ក្នុងរយៈពេលនេះចំណីដែលដាក់អោយជ្រូកស៊ីមានអង្ករ ១កំប៉ុងកន្លះដាំជាបាយ ឬ បបរគោកកន្ទក់១គីឡូកន្លះនិងបន្លែ ច្រាច់៣គីឡូក្រាមច្របល់លាយចូលគ្នា ដាក់ទឹកភក់អោយ ជ្រូកស៊ី ១ថ្ងៃ ២ដង។
-ជ្រូកចាប់ពីអាយុ៤ខែឡើងទៅកសិករអាចអោយរុក្ខជាតិចកបាយទាចំនួន៤គីឡូក្រាមអង្ករ២កំប៉ុងដាំជាបាយ ឬ បបរគោកលាយកន្ទក់១គីឡូកន្លះដាក់ច្របល់ជាមួយទឹកភក់ៗ អោយជ្រូកស៊ី១ថ្ងៃ២ ដង។ (ប្រភពៈព្រឹត្តិប័ត្រ កសិករ បោះផ្សាយ ដោយ